# កម្មវិធីស្ត្រីក្នុងក្តីសង្ឃឹម

## មេរៀនជីវិត: ការស្រែកគំហករបស់ម្តាយ

## មេរៀនព្រលឹងវិញ្ញាណ: តើព្រះឆ្លើយតបនឹងសំណូមអធិស្ឋានរបស់យើងដែរអត់?

## សេចក្តីផ្តើម

…………………………………………………………..ភ្លេង…………………………………….

**បូផា:** ចាស កម្មវិធីស្ត្រីក្នុងក្តីសង្ឃឹម សូមស្វាគមន៍ និងសូមជំរាបសួរដល់ប្រិយ៍មិត្តអ្នក ស្តាប់ទាំងអស់។ នៅសប្តាហ៍នៅតែជួបជាមួយ ខ្ញុំ បូផា និងណារីដដែរ។ ចាស បងប្អូនស្ត្រី តើកូនរបស់អ្នកធ្លាប់ធ្វើដូច្នេះអត់? គឺធ្វើអោយអ្នកខឹង និងទ្រាំមិនដំឡើងសំលេងខ្លាំងៗ។

**ម្តាយ:** ម៉ាក់បានប្រាប់ម្តងហើយ ម្តងទៀតថា កុំអោយបោះកាតាប និងអីវ៉ាន់ប៉ាតណាប៉ាតណី ពេលមកពីសាលាវិញ។ ម៉េចប្រាប់ហើយនៅតែមិនធ្វើតាមចឹង?

**ណារី:** ចាស បងប្អូនស្ត្រី ខ្ញុំជឿថា អ្នកពិតជាមិនចង់ប្រើវិធីស្រែកគំហកដាក់កូន ដើម្បីអោយកូនៗស្តាប់នោះទេ មែនទេ? តែកូនៗរបស់អ្នកពិតជាពិបាកនឹងស្តាប់ណាស់ មែនទេ? ចាស ហើយការនេះមិនមែនកើតលើតែបងប្អូនប៉ុណ្ណោះទេ តែការនេះក៏កើតដដែរៗចំពោះស្ត្រីទូទាំងពិភពលោក។ ដូច្នេះ នៅថ្ងៃនេះ កម្មវិធីស្ត្រីក្នុងក្តីសង្ឃឹម នឹងជជែកគ្នាពីការនេះ។

…………………………………………ភ្លេង ……………………………………………………………….

## មេរៀនជីវិត: ការស្រែកគំហករបស់ម្ដាយ

**បូផា:** ចាស ណារី យើងមើលឃើញថា ការដាក់វិន័យ និងការប្រដៅតំរង់កូនៗ ដែលជាច្រើនដងធ្វើអោយយើងឈឺក្បាលណាស់ ហើយ ការចិញ្ចឹមបីបាច់ថែរក្សាកូនដល់ធំ គឺមិនមែនជាការងាយស្រួលទេ មែនទេ?

**ណារី:** ចាស ពិតមែនហើយបង តែយើងក៏មានអំណរដដែរ បើទោះបីជាពេលខ្លះយើងខឹងកូនរហូតដល់ស្រែកគំហកដាក់កូនខ្លាំងៗក៏ដោយ។ ខ្ញុំគិតថា បងប្អូនស្ត្រីរបស់យើងក៏ចង់ដឹងដែរថា ហេតុអ្វីបានជាអ្នកម្ដាយចូលចិត្តស្រែកដាក់កូនខ្លាំងៗយ៉ាងនេះ ទោះបីជាគាត់មិនចង់ក៏ដោយ?

**បូផា:** ចាស ពិតមែនហើយអូន ហើយប្រហែលជាបងប្អូនស្ត្រីរបស់យើងចង់ដឹងខ្លាំងដែរហើយមើលទៅ ព្រោះអីមានបងប្អូនយើងខ្លះក៏នឹងក្លាយជាអ្នកម្ដាយដែរ។ ចាស បងប្អូនស្ត្រី បើតាមខ្ញុំសង្កេតមើលឃើញថា ភាគច្រើនអ្នកម្ដាយដែលស្រែកដាក់កូន ព្រោះពួកគាត់មានការងារជាច្រើនដែលត្រូវធ្វើ ដោយគ្មានពេលគ្រប់គ្រាន់ដើម្បីធ្វើកិច្ចការទាំងអស់នោះ ដូច្នេះហើយធ្វើអោយពួកគាត់ស្មុគស្មាញ ហើយចាប់ផ្ដើមធ្វើអ្វីចេះតែខុស។ ចាស បងប្អូនស្ត្រី តើអ្នកធ្លាប់មានអារម្មណ៍បែបនេះអត់? គឺចាប់ធ្វើនេះក៏ខុស ធ្វើនោះក៏ខុស ហើយម្ហូរមៅតែម្ដង។

**ណារី:** ចាស ពិតមែនហើយបង។ មានបងស្រីម្នាក់ដែលជាអ្នកជិតខាងខ្ញុំមួយ គឺនៅពេលមួយដែលកូនគាត់ធ្វើកំពប់ទឹករាងច្រើនបន្តិចនោះ គាត់ក៏ស្រែកដាក់កូនគាត់ខ្លាំងៗ ហើយធ្វើអោយកូនរបស់គាត់ភ័យមែនទែន តែខ្ញុំគិតថា បើបងស្រីនោះមិនធ្វើចឹងទេ កូនគាត់នៅតែរពឹស និងមិនព្រមស្ដាប់គាត់ដដែរ។

**បូផា:** ចាស អូន ការដែលស្រែកដាក់កូននេះ វាក៏ជាការមួយដើម្បីធ្វើអោយកូនយើងស្ដាប់យើងដែរ ដែលយើងជាម្ដាយមានចិត្តមួយមិនចង់អោយកូនធ្វើអ្វីខុសទេ។ នៅពេលដែលកូនៗធ្វើអោយអ្នកម្ដាយខឹងម្ដងៗ អ្នកម្ដាយប្រហែលជាពិបាកទ្រាំណាស់ មែនទេ? ហើយពួកគាត់ចង់តែស្រែកដាក់កូនវិញទេ ប៉ុន្តែបងប្អូនស្ត្រី អ្នកត្រូវតែរំលឹកខ្លួនឯងថា នរណាក៏មានកំហុសដែរ ដើម្បីអោយយើងអាចទប់ចិត្តបាន និងមិនស្ដីអោយកូនខ្លាំងៗ។

**ណារី:** ចាស ពិតមែនហើយបង ហើយខ្ញុំជឿថា ការដែលយើងនិយាយជាមួយកូនយើង ដោយពាក្យសំដីល្អៗ ពិរោះៗ វាប្រសើរជាងការដែលយើងជេរប្រទេចកូន។ ចាស ហើយជាការពិតដែលមនុស្សយើងមួរម៉ៅគ្រប់គ្នា មែនទេ? ប្រសិនបើមានកូន ឬនរណាម្នាក់ធ្វើអ្វីខុសចិត្តយើង ក៏ប៉ុន្តែមិនមែនមានន័យថា ការនេះយើងកែមិនបាននោះទេ ដូចជាអ្វីដែលខ្ញុំធ្លាប់លឺអញ្ចឹងថា ស្ត្រីខ្មែរយើងពូកែទ្រាំណាស់ ដូច្នេះការទ្រាំទប់កំហឹងរបស់យើង ក៏អាចជួយកែតំរង់កូនរបស់យើងដោយវិធីល្អៗផងដែរ។

**បូផា:** ចាស ពិតមែនហើយអូន ដូចអូននិយាយអញ្ចឹងថា ពេលខ្លះយើងមួរម៉ៅមែនទែន គឺគ្មាននរណាម្នាក់មិនចេះមួរម៉ៅនោះទេ មែនទេ? ជាពិសេសនៅពេលដែលយើងមានអារម្មណ៍មិនល្អ ដូចជាឈឺក្បាល វិលមុខ ហើយល្វើយជាដើម។ តើអ្នកធ្លាប់មានអារម្មណ៍បែបនេះដែរអត់?

**ណារី:** ចាស បងពេលបងនិយាយពីនិយាយចឹង ធ្វើអោយខ្ញុំនឹងឃើញពីសកម្មភាពស្តែងនឹងភ្នែកមួយ គឺ ថ្ងៃមួយនោះ នៅពេលដែលមានម្តាយម្នាក់ ដូចថា រៀងមិនសូវស្រួលខ្លួនស្រាប់តែកូនៗរបស់គាត់ប្រកែកគ្នា ដណ្តើមអ្វីមួយ ហើយសំលេងពួកកូនគាត់ ង៉ូវៗនៅជិតគាត់ ពេលនោះធ្វើអោយគាត់មិនអាចទប់ចិត្តស្រែកគំហកដាក់មិនបាន។ ចាស ហើយខ្ញុំជឿថាបងប្អូនស្ត្រី ដែលមានកូនពិតជាយល់ពីការនេះមិនខាន មែនទេបង?

**បូផា:** ចាស អូន នៅពេលដែលយើងបញ្ចេញកំហឹងរបស់យើងចំពោះកូនដូច្នេះ វាធ្វើអោយពូមីង ប្តី ឬ អ្នកនៅជុំវិញខ្លួនយើង ក៏មានអារម្មណ៍មិនល្អទៅតាមយើងដែរ។ ដូច្នេះជាការល្អមួយ ដែលបងប្អូនអាចធ្វើបាននោះ គឺនៅពេលដែលបងប្អូនកំពុងតែមានកំហឹងខ្លាំងជាមួយកូនបងប្អូននោះ បងប្អូនគួរតែឈប់មួយស្របក់ រួចដកដង្ហើយចេញចូល អោយវែងៗមួយសន្ទុះសិនជាការល្អ។ ការធ្វើដូច្នេះ ជួយអោយយើងមានពេលគិតរកវិធីណាមួយល្អសំរាប់ពន្យល់ប្រាប់កូនៗរបស់យើង។ មានពេលមួយដែលប្អូនស្រីបងគាត់មិនសូវស្រួលខ្លួន គាត់បានប្រាប់ទៅកូនរបស់គាត់ នៅពេលដែលគាត់ឈឺ ដើម្បីអោយកូនគាត់អាចជួយដល់គាត់បាន។ ការ

ដែលយើងហ៊ានប្រាប់កូនរបស់យើង និងក្រុមគ្រួសារយើងនោះ វាក៏ជាការល្អមួយផងដែរ។ បើមិនប្រាប់ ធ្វើម៉េចបានពួកគេដឹង មែនទេ?

**ណារី:** ចាស បងបូផា ខ្ញុំសង្ឃឹមថា គំនិតនេះអាចជួយបងប្អូនអ្នកស្តាប់ទាំងអស់បានខ្លះៗដែរ។ ចាស តើបងគិតថា មានការអីទៀតដែលធ្វើអោយអ្នកម្តាយស្រេកគំហាកដាក់កូននោះ?

**បូផា:** ចាស អូន បងគិតថា ការដែលអ្នកម្តាយស្រេកគំហាកដាក់កូន គឺអាចមកពីការរស់នៅមានរបៀបរាប់រយរបស់គាត់ផងដែរ។ បងប្អូនស្រ្តី តើអ្នកចង់អោយផ្ទះរបស់យើងមានរបៀបរៀបរយល្អឥតខ្ចោះទេ? តើអ្នកចង់មានកូនដែលល្អគ្រប់លក្ខណ៍ទេ? ចាស ណារី បងគិតថា ការនេះមិនអាចគ្រប់លក្ខណ៍ ឬ ល្អឥតខ្ចោះនោះទេ។ គឺមានព្រះតែមួយអង្គគត់ដែលគ្រប់លក្ខណ៍។ ព្រះអង្គមិនដែលចង់ទទួលការល្អឥតខ្ចោះរបស់យើងនោះទេ ទ្រង់គ្រាន់តែចង់បានសេចក្តីស្រលាញ់ និងការស្តាប់បង្គាប់ពីយើងគ្រប់ៗគ្នាប៉ុណ្ណោះ។ ទ្រង់ក៏ចង់អោយយើងបង្រៀនការនេះទៅដល់កូនយើងផងដែរ ព្រោះព្រះប្រទានកូនៗមកអោយយើង ដើម្បីអោយយើងបានស្រលាញ់ ហើយបង្រៀនកូនៗអោយចេះប្រើពាក្យសំដី និងសកម្មភាពសុភាពរាបសារ។

**ណារី:** ចាស ដូច្នេះបងប្អូនស្រ្តី ក្នុងនាមយើងជាម្តាយម្នាក់ យើងគួរតែនិយាយមឹងម៉ាត់ជាមួយកូន គឺបានន័យថា យើងនិយាយអ្វីអោយច្បាស់ទៅកូនយើង ដើម្បីអោយពួកគាត់បានយល់ពី

អ្វីដែលយើងចង់និយាយប្រាប់។ ក្មេងៗនឹងធ្វើតាមយើង នៅពេលដែលពួកគេយល់ពីអ្វីដែលអ្នកចង់ប្រាប់។

**បូផា:** ចាស ម្យ៉ាងវិញទៀត បងប្អូនស្ត្រី យើងគួរតែមានការបត់បែនទៅតាមកាលៈទេសៈផងដែរ ហើយអាកប្បកិរិយារបស់យើង គឺគួរតែវិជ្ជមានជានិច្ច។ ចាស ហើយការដែលយើងចេះបត់បែនទៅតាមកាលៈទេសៈនេះ គឺវាសំខាន់ណាស់សំរាប់អ្នកម្តាយ។ អ្វីៗដែលយើងដាក់អោយកូនយើងធ្វើតាម ត្រូវធ្វើសន្សឹមៗ ហើយបើមានការណាមួយចាំបាច់ ត្រូវផ្លាស់ប្តូរ គួរតែផ្លាស់ប្តូរផងដែរ គឺដោយយើងរកវិធីផ្សេងទៀតមកជំនួសវិញ។

**ណារី:** ចាស ហើយចំពោះកាយវិការ និងពាក្យសំដីយើងក៏សំខាន់ដែរ បើយើងនិយាយពាក្យល្អៗ ណែនាំកូនយើងនោះ មិនយូរទេអ្នកនឹងឃើញពីការផ្លាស់ប្តូររបស់កូនៗយើង។ ចាស ហើយជាចុងក្រោយ ខ្ញុំសូមលើកទឹកចិត្តបងប្អូនថា សូមព្យាយាមក្នុងការអធិស្ឋាន សូមអោយព្រះអង្គផ្តល់ប្រាជ្ញា និងដឹកនាំយើងក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនយើងអោយបានល្អ។ ខ្ញុំជឿថា ព្រះទ្រង់នឹងប្រទានដល់បងប្អូនទាំងអស់គ្នាជាក់ជាមិនខាន។

**បូផា:** បងប្អូនស្ត្រី មេរៀនជីវិតយើងនៅថ្ងៃនេះ បានចូលមកដល់បញ្ចប់ហើយ យើងខ្ញុំសង្ឃឹមថា មេរៀននេះនឹងជាជំនួយខ្លះៗដល់បងប្អូន។ ចាស មុនចូលដល់មេរៀនខាងឯព្រលឹងវិញ្ញាណ សូមចូលរួមស្តាប់បទចំរៀងមួយបទសិន។ ចាស សូមអញ្ជើញ

……………………………………………………….ចំរៀង ………………………………………………….

## មេរៀនព្រលឹងវិញ្ញាណៈ តើព្រះឆ្លើយតបនឹងសំណូមអធិស្ឋានរបស់យើងដែរអត់?

**ណារីៈ** ចាស បងប្អូនស្រ្តី តើអ្នកធ្លាប់មានចិត្តសង្ស័យថា នៅពេលដែលបងប្អូនអធិស្ឋាន តើព្រះឆ្លើយបតការអធិស្ឋានរបស់ខ្ញុំអត់ទេនេ៎? ចាស បើសិនជាបងប្អូនធ្លាប់មានកាលនេះ សូមកុំទាន់អាលស្រយុតចិត្ត ហើយសូមមកតាមដានស្ដាប់នៅក្នុងមេរៀនខាងឯវិញ្ញាណរបស់យើងនៅថ្ងៃនេះ ដែលនឹងនិយាយគ្នា ថា តើព្រះឆ្លើយតបនឹងសំណូមអធិស្ឋានរបស់យើងដែរអត់? ចាស សូមបានចូលរួមស្ដាប់ទាំងអស់គ្នា។

**បូផាៈ** ចាស ណារី មុននឹងចាប់ផ្ដើមមេរៀនរបស់យើង បងសូមលើកជាឧទាហរណ៍មួយប្រាប់ទៅដល់បងប្អូនយើងបន្ដិច។ ប្រសិនបើកូនរបស់យើងមានបញ្ហាត្រូវការអ្វីមួយ ពួកគេមកជួបអ្នក ហើយសុំអោយអ្នកជួយនោះ តើអ្នកជួយកូនអ្នកអត់?

**ណារីៈ** ចាស បង ខ្ញុំគិតថា ១០០ភាគរយ បងប្អូនយើងប្រាកដជាឆ្លើយថា ជួយហើយ មែនទេ?

**បូផាៈ** ចាស ពិតមែនហើយអូន។ បងប្អូនស្រ្តី មានពេលមួយនោះ ព្រះយេស៊ូបានបង្រៀនដល់បណ្ដាលជនជាច្រើន។ ទ្រង់បានបង្រៀនគេពីការល្អសំរាប់ជីវិតរស់នៅរបស់ពួកគេ។ ហើយទ្រង់ក៏បានបង្រៀនដល់ពួកគេផងដែរ ពីការអធិស្ឋាន។ នេះជាអ្វីដែលទ្រង់បានមានបន្ទូលទៅពួកគេ គឺក្នុងព្រះគម្ពីរម៉ាថាយ ៧:៩-១១ ថា " **ក្នុងចំណោមអ្នករាល់គ្នា បើកូនសុំនំប៉័ង មិនដែល**

**មាននរណាយកដុំថ្មអោយវាឡើយ។ ហើយបើកូនសុំត្រី ក៏មិនដែលមាននរណាយកពស់អសិរពិសអោយវាដែរ។ សូម្បីតែអ្នករាល់គ្នាដែលជាមនុស្សអាក្រក់ ក៏ចេះអោយរបស់ល្អៗទៅកូន ចុះចំណង់បើព្រះវរបិតារបស់អ្នករាល់គ្នា ដែលគង់នៅស្ថានបរមសុខ តើព្រះអង្គនឹងប្រទានអ្វីៗដ៏ល្អៗអោយអស់អ្នកដែលទូលសូមពីព្រះអង្គ យ៉ាងណាទៅទៀត!״ ។**

**ណាវី:** ចាស បងប្អូនស្ត្រី ឥឡូវនៅក្នុងព្រះគម្ពីរម៉ាថាយដដែរ នៅក្នុងជំពូក ៧:៧-៨ បានប្រាប់ទៀតថា ‟ **ចូរសុំ នោះព្រះជាម្ចាស់នឹងប្រទានអោយអ្នករាល់គ្នា ចូរស្វែងរក នោះអ្នករាល់គ្នានឹងបានឃើញ ចូរគោះទ្វារ នោះព្រះអង្គនឹងបើកអោយអ្នករាល់គ្នាជាពុំខាន។ ដ្បិតអ្នកណាសុំអ្នកនោះតែងតែបានទទួល អ្នកណាស្វែងរកអ្នកនោះតែងតែបានឃើញ ហើយគេតែងតែបើកទ្វារអោយអ្នកដែលគោះ។״** ចាស បងប្អូនស្ត្រី តើព្រះឆ្លើយតបនឹងការអធិស្ឋានរបស់អ្នកដែរអត់?

**បូផា:** ចាស បងប្អូនស្ត្រី ព្រះពិតជាប្រទានអោយយើង បើសិនជាយើងចូលទៅកាន់ទ្រង់ ហើយទូលសូមដល់ទ្រង់ ហើយបើយើងរកនោះពិតជាឃើញជាក់ជាមិនខាន។ ចាស នេះពិតជាអស្ចារ្យមែនទែន! ចាស ហើយខ្ញុំនឹងប្រាប់បងប្អូនពីរឿងមួយ ដែលដកស្រង់ក្នុងព្រះគម្ពីរដែលនិយាយពី រឿងរបស់នាងហាណា ដែលបានដកស្រង់ចេញពីក្នុងព្រះគម្ពីរ១សាំយូអែល១ ។ ប៉ុន្តែមុននឹងយើងខ្ញុំទាំងពីរនិយាយពីរឿងរបស់នាងហាណា ខ្ញុំចង់ប្រាប់បងប្អូនពីកម្មវិធីស្ត្រីក្នុងក្តីសង្ឃឹមរបស់យើងនៅថ្ងៃនេះថា កម្មវិធីស្ត្រីក្នុងក្តីសង្ឃឹមជាផ្នែកមួយនៅក្នុងគោលការណ៍

ហាណា របស់អង្គការគ្រីស្ទានរើលកម្ពុជា។ ហើយនៅជុំវិញពិភពលោកមានស្ត្រីរាប់លាននាក់កំពុងអធិស្ឋានអោយស្ត្រីផ្សេងៗទៀតនៅជុំវិញពិភពលោក ជាពិសេសយើងបានអធិស្ឋានអោយស្ត្រី ដែលរស់នៅក្នុងការឈឺចាប់ និងរងគ្រោះដោយសារអំពើហឹង្សា។ អស់រយៈពេលជាច្រើនឆ្នាំមកហើយ រហូតមកដល់សព្វថ្ងៃនេះ ចំនួនស្ត្រីដែលចូលរួមអធិស្ឋាន ដោយប្រើប្រតិទិនអធិស្ឋាន មានការកើតឡើងជារៀងរាល់ខែ។ ហើយកម្មវិធីស្ត្រីក្នុងក្តីសង្ឃឹម ក៏បានផ្សព្វផ្សាយចេញទៅដល់ប្រទេសជាច្រើននៅជុំវិញពិភពលោក និងមានភាសាផ្សេងៗគ្នា។ បានជាយើងដាក់ឈ្មោះថា គោលការហាណា ព្រោះហាណាជាស្ត្រីម្នាក់ដែលចូលចិត្តអធិស្ឋាន។ នាងបានអធិស្ឋានទៅកាន់ព្រះទាំងទុក្ខព្រួយ និងបង្ហូរទឹកភ្នែក ហើយព្រះទ្រង់ជ្រាបពីសេចក្តីអធិស្ឋានរបស់នាង។

**ណារី:** ចាស អរគុណបងបូផា ដែលបានប្រាប់ពីគោលការណ៍ហាណា។ ឥឡូវខ្ញុំ និងបងបូផានឹងប្រាប់បងប្អូនពីរឿងរបស់នាងហាណាវិញ។ លោកអែលកាណា មានប្រពន្ធពីរនាក់ ប្រពន្ធទីមួយរបស់គាត់ឈ្មោះថា ហាណា ហើយម្នាក់ទៀតឈ្មោះថា ពេនីណា។ នៅក្នុងសម័យនោះការដែលមានប្រពន្ធពីរជាការធម្មតាទេ នៅក្នុងព្រះគម្ពីរបានប្រាប់ថា " នាងពេនីណាមានកូនតែនាងហាណាគ្មានកូនទេ"។ ដូច្នេះហើយបានជានាងហាណាព្រួយចិត្តដូច្នេះ។ តែការដែលនាងយំពិបាកចិត្តនោះ គឺមិនមែនមកពីនាងគ្មានកូននោះទេ តែនាងយំពិបាកចិត្តដោយសារតែនាងពេនីណាសើចចំអក និងបៀតបៀននាង ដោយសារតែនាងហាណាគ្មានកូន។

**បូផា:** ជារៀងរាល់ឆ្នាំ លោកអែលកាណាតែងតែធ្វើដំណើរពីភូមិរបស់គាត់ ដើម្បីទៅថ្វាយបង្គំព្រះអម្ចាស់នៅស៊ីឡូ ព្រមទាំងថ្វាយយញ្ញបូជាផងដែរ។ នៅថ្ងៃថ្វាយយញ្ញបូជា លោកអែលកាណាមានទម្លាប់យកសាច់ទៅអោយនាងពេនីណាជាប្រពន្ធ និងកូនប្រុស កូនស្រីទាំងអស់របស់នាង មួយចំណែកម្នាក់ ប៉ុន្តែចំណែកនាងហាណាវិញ គាត់បានអោយមួយទ្វេជាពីរ ព្រោះគាត់ស្រលាញ់នាងច្រើនជាង ទោះបីជាព្រះជាម្ចាស់បានធ្វើអោយនាងគ្មានកូនក៏ដោយ។ នាងពេនីណាជាគូវិវាទ តែងតែរុកគួន បញ្ឈឺចិត្តនាងហាណា ក្នុងគោលបំណងអោយនាងខឹងនឹងព្រះជាម្ចាស់ ដែលមិនបានប្រទានអោយនាងមានកូន ហើយធ្វើអោយនាងហាណាយំមិនព្រមបរិភោគអ្វីសោះឡើយ។

**ណារី:** ពេលនោះ លោកអែលកាណាជាប្តី សួរទៅនាងហាណាថា " ហាណាអើយ! ហេតុអ្វីបានជានាងយំ? ហេតុអ្វីបានជានាងមិនបរិភោគដូច្នេះ? ហេតុអ្វីបានជានាងព្រួយចិត្ត ឬមួយខ្ញុំគ្មានតម្លៃស្មើនឹងកូនដប់នាក់ទេឬ? ទោះបីជានាងហាណាមានទុក្ខយ៉ាងណាក៏ដោយ នាងក៏បានធ្វើការដ៏ឈ្លាតវៃមួយ គឺនាងទៅព្រះវិហារ ហើយអធិស្ឋានទៅរកព្រះជាម្ចាស់។ នាងយំទូលអង្វរដល់ព្រះទាំងទឹកភ្នែក ដើម្បីអោយទ្រង់ប្រទានបុត្រាមួយដល់នាង។

**បូផា:** ចាស បងប្អូនស្រ្តី នាងបានអធិស្ឋានថា " ឱ! ព្រះអម្ចាស់នៃពិភពទាំងមូលអើយ! សូមទតមកខ្ញុំម្ចាស់ ដែលកំពុងតែមានទុក្ខព្រួយ សូមនឹកដល់ខ្ញុំម្ចាស់ ហើយកុំបំភ្លេចខ្ញុំម្ចាស់ឡើយ។ ប្រសិនបើព្រះអង្គប្រោសប្រទានអោយខ្ញុំម្ចាស់មានកូនប្រុសមួយ ខ្ញុំម្ចាស់នឹងយកកូនមក

ថ្វាយព្រះអង្គ ដើម្បីអោយនៅបំរើព្រះអង្គអស់មួយជីវិត ហើយសក់វានឹងមិនត្រូវកោរ ឬ កាត់ឡើយ”។ ក្រោយមក នាងហាណាក៏មានកូនប្រុសមួយមែន។ នាងបានដាក់ឈ្មោះកូនប្រុសថា “ សាំយូអែល” ដែលមានន័យថា កូននេះបានមកពីព្រះជាម្ចាស់។ នាងហាណាបានគោរពតាមពាក្យសន្យាដែលគាត់បាននិយាយទៅកាន់ព្រះ ដោយថ្វាយកូននោះដល់ទ្រង់ និងកុមារសាំយូអែល នៅបំរើព្រះជាម្ចាស់ជាមួយលោកបូជាចារ្យអេលី។

**ណាវី:** បងប្អូនស្ត្រី តើព្រះឆ្លើយតបនឹងសំណូមអធិស្ឋានឬទេ? ចាស ទ្រង់ពិតជាឆ្លើយតបតាមសំណូមអធិស្ឋានរបស់យើង គឺដូចជានាងហាណាចឹងដែរ។ ព្រះជាម្ចាស់នឹងឆ្លើយតបតាមវិធីរបស់ទ្រង់ គឺមានន័យថា តាមពេលវេលារបស់ទ្រង់ ហើយទ្រង់នឹងមានចំលើយដ៏ល្អបំផុតមួយសំរាប់យើងរាល់គ្នា ហើយចំលើយរបស់ទ្រង់ប្រហែលជា បាន, ត្រូវការរង់ចាំសិន ឬ មិនបានទេ ព្រោះអីការខ្លះដែលយើងសូម មិនមែនជាការល្អសំរាប់យើងទេ។ ពេលខ្លះ ទ្រង់ឆ្លើយតបហួសពីអ្វីដែលយើងត្រូវការទៅទៀត។

**បូផា:** ចាស បងប្អូនស្ត្រី ព្រះជាម្ចាស់ គឺជាឪពុកដែលពេញទៅដោយសេចក្ដីស្រលាញ់ ហើយទ្រង់រកចាំកូនរបស់ទ្រង់ទៅរកទ្រង់ជានិច្ច។ អ្នកអាចនិយាយទៅកាន់ទ្រង់នៅពេលនេះ កន្លែងដែលបងប្អូនកំពុងអង្គុយនេះ នោះទ្រង់នឹងផ្ទៀងព្រះការណ៍ស្ដាប់ ហើយឆ្លើយតបដល់ការអធិស្ឋានរបស់បងប្អូន ព្រោះព្រះអង្គមានវត្តមានគ្រប់ទីកន្លែងទាំងអស់។ ប្រសិនជានៅពេលនេះ ចិត្តរបស់អ្នកកំពុងតែឈឺចាប់ សូមបានអធិស្ឋានជាមួយខ្ញុំផងដែរ។ សូមបានអធិស្ឋាន

ទាំងអស់គ្នា " ព្រះអង្គអើយ កូនអរគុណព្រះអង្គ ដែលទ្រង់បានបង្កើតទូលបង្គំមកជាមិត្តរបស់ទ្រង់។ អរគុណព្រះអង្គដែលបានចាត់ព្រះយេស៊ូគ្រីស្ទមកផែនដីយើងនេះ ដើម្បីសង្គ្រោះបាបយើង ហើយនិងដើម្បីអោយយើងបានក្លាយជាកូនរបស់ទ្រង់។ ព្រះអង្គជ្រាបពីទុក្ខព្រួយរបស់ទូលបង្គំ សូមទ្រង់ជួយដោះស្រាយ និងបង្ហាញផ្លូវដល់ទូលបង្គំផង។ សូមជួយអោយទូលបង្គំបានទុកចិត្តទ្រង់ ហើយជឿថា ទ្រង់នឹងឆ្លើយតបនូវសំណូមអធិស្ឋានរបស់កូននៅពេលណាមួយ។ ទូលបង្គំ សូមថ្វាយការទាំងអស់នេះ នៅក្នុងព្រះនាមព្រះយេស៊ូគ្រីស្ទ។ អាម៉ែន!!

**កំណាប់មរតក**

**ណារី:** ចាស បងប្អូនស្រ្តី មេរៀនព្រលឹងវិញ្ញាណរបស់យើងនៅថ្ងៃនេះ បានបញ្ចប់ហើយ។ ចាស ហើយនៅក្នុងនាទីកំណាប់មរតករបស់យើងវិញ យើងនឹងលើកយកចំរៀងមួយបទ ដើម្បីចែកជូនបងប្អូនស្តាប់ទាំងអស់គ្នា សូមបានចូលរួមសណ្តាប់ដូចតទៅ

**ភ្លេង**…………………………………….

**ណារី:** ចាស បងប្អូនស្រ្តី កម្មវិធីស្រ្តីក្នុងក្តីសង្ឃឹមបានដល់ពេលវេលា ដែលត្រូវគោរពលាដល់បងប្អូនស្រ្តីហើយ។ ចាស យើងទាំងពីរនាក់សង្ឃឹមថា ពីកម្មវិធីយើងនៅថ្ងៃនេះ នឹងបានលើកទឹកចិត្តដល់បងប្អូនទាំងអស់គ្នា ហើយក៏សង្ឃឹមថា បងប្អូននឹងយកអ្វីដែលយើងខ្ញុំ

បានជំរាបជូន នៅថ្ងៃនេះទៅពិចារណាផងដែរ។ ប្រសិនបើបងប្អូនមានចំងល់ បងប្អូនអាចទំនាក់ទំនងមកកាន់តាមរយៈទូរសព្ទលេខ ០៩២ ៦០ ៦០ ៥១ និង ០៨៨ ៩៥៦ ៩៩ ៥៥។

**ប្ញជា:** កម្មវិធីស្ត្រីក្នុងក្តីសង្ឃឹម ផលិតដោយអង្គការត្រែសន៍រើលកម្ពុជា។ កម្មវិធីស្ត្រីក្នុងក្តីសង្ឃឹម សូមលំអោនកាយជំរាបលា ប្រិយមិត្តអ្នកស្តាប់ត្រឹមប៉ុណ្ណេះសិន។ សន្យាថានឹងវិលមកជួបគ្នាម្តងទៀត នៅសប្តាហ៍ក្រោយ តាមពេលវេលាដដែល ម៉ោងដដែល។ សូមព្រះប្រទានពរ!!